December 28th 2006
Rhode Island of United State of America
3 Fountain Cranston, RI 02920

លិខិតចំហរ ដោយចំពោះ និងជាបុគ្គល

របស់ខ្ញុំ សួន សេរីរដ្ឋា

ជូន លោក នរោត្តម សីហនុ

អតិតប្រមុខរដ្ឋ នៃកម្ពុជា

លោក ជាទី គោរពរាប់អាន

ខ្ញុំបានអានអត្ថបទរបស់លោក ក្រោមចំណងជើងថា ***ថ្ងៃចុងក្រោយនៃរបប ប៉ុល ពត និងរូបខ្ញុំ*** ដែលត្រូវបានសារព័ត៌មានក្នុងស្រុកយកមកបកប្រែ និងធ្វើការចុះផ្សាយ វាហាក់ដូចជាបង្ហាញថា ខ្លួនរបស់លោក ដែលជាស្ថាបនិករបបខ្មែរក្រហម និងជា អតិតប្រមុខរដ្ឋនៃរបបខ្មែរក្រហម ព្រមទាំងក្រុមគ្រួសាររបស់លោក ពិតជាមិនដឹងខ្យល់អ្វីសោះអំពីរបបមួយដែលបានសំលាប់ប្រជាពលរដ្ឋខ្លួនឯងយ៉ាងរង្គាលបែបនេះ។ រឿងល្ខោន ដែលនិពន្ធ ដឹកនាំរឿង និងសំដែងដោយខ្លួនលោកផ្ទាល់ ហើយចុងបញ្ចប់លោកបែជានិយាយថា លោកមិនដឹងពីអត្ថន័យ នៃរឿងនោះទៅវិញ នោះមិនមានន័យថា លោកកំពុងតែមើលងាយទស្សនិកជនរបស់លោកទេ ឬមួយយ៉ាងណា?

ប្រយោគដែលសរសេរថា លោក និងកូនរបស់ប្រុសរបស់លោក (នរោត្តម សីហមុនី) បានផ្លាស់ប្តូរគំនិតគ្នាយ៉ាងស្ងប់ស្ងាត់ ជាមួយនិងស្នាមញញឹម ពោពេញដោយក្តីសង្ឃឹមនិងការរីករាយ គឺការកើតឡើងនៃរណសិរ្សរំដោះជាតិ ដែលដឹកនាំដោយ លោក ហេង សំរិន។ តើមានន័យយ៉ាងដូចម្តេច? ឬមួយវាគ្រាន់តែជាការបំពេញចិត្ត ឬក៏ជាការបំពេញអត្ថន័យអោយសំណេររបស់លោក ដែលលោក បានការពារថ្ងៃ ៧ មករា ដែលជាថ្ងៃដែលយួនចូលមកឈ្លានពាន និងដាក់នឹមអាណានិគមមកលើប្រទេសខ្មែរ? បើមានន័យដូច្នោះមែន លោក និងក្រុមគ្រួសាររបស់លោក គឺជាមនុស្សក្បត់ជាតិ ជាគ្រួសារក្បត់ជាតិ និងច្បាស់ក្រឡែតបង្ហាញថា លោកគឺជាមេចលករដែលដឹកនាំការសំលាប់ជីវិតប្រជាពលរដ្ឋខ្មែររាប់លាននាក់ ដោយមិនអាចប្រកែកបាន។ ហេតុផលទី១ គឺលោកប្រកាស់អោយខ្មែរអ្នកស្នេហាជាតិចូលព្រៃម៉ាគី ប្រឆាំងរបបសាធារណៈរដ្ឋខ្មែរ ដែលក្រោយមកចលនាព្រៃម៉ាគី

របស់លោកក្លាយទៅជារបបវាលពិឃាតខ្មែរក្រហម និងទី២ គឺការអំពានាវអោយប្រជាពលរដ្ឋអ្នកស្នេហាជាតិ ចូលក្នុងរណសិរ្សរួបរួមជាតិ កម្ពុជា ឯករាជ្យ សន្តិ និងសហប្រតិបត្តិការ ដែលក្រោយមកក្លាយទៅជា ហ៊្វុនស៊ិនប៉ិច។ នោះគឺសុទ្ធតែនាំអោយប្រជាពលរដ្ឋខ្មែរទៅស្លាប់ទាំងអស់ក្រោមលែស ដេញយួន និងអាយ៉ងយួន តែតាមការពិតគឺលោក និងក្រុមគ្រួសាររបស់លោកគ្រាន់តែចង់វិលមកធ្វើជាស្តេច ដើម្បីមានខ្ញុំកំដរ បរិវា និងស្រីស្នំមុខក្រោយតែប៉ុណ្ណោះ។ វាជាប្រវត្តិសាស្ត្រដ៏សែនឃើចាប់បំផុត ដែលលោកចំណាយជីវិតប្រជាពលរដ្ឋខ្មែររាប់លាននាក់ ដើម្បីភាពរុងរឿង និងមហិច្ឆតា តណ្ហា របស់លោក និងក្រុមគ្រួសារលោក។ តើទង្វើ និងការដឹកនាំដ៏ថោកទាបបែបនេះ គួរតែប្រឈមមុខអោយប្រជាពលរដ្ឋ និងជនរងគ្រោះកម្ពុជា កាត់ទោសលោកដែរឬទេ?

ប្រយោគដែលសរសេរថា លោក មានការភ្ញាក់ផ្អើលពេលដែលលោកបានជួប ប៉ុល ពត ក្នុងនាទីចុងក្រោយ ហើយ ប៉ុល ពត គឺជាមនុស្សដែលលោកធ្លាប់ស្គាល់នៅក្នុងតំបន់រំដោះថា គឺជាសាឡុត ស ដែលលោកធ្លាប់ជួបកាលពីឆ្នាំ១៩៧៣។ តើពិតទេ? គួរអោយអស់សំណើចទេ? ដែលប្រមុខរដ្ឋដូចលោក មិនដែលបានជួប ឬស្គាល់ បុគ្គលជានាយករដ្ឋមន្ត្រី ក្នុងរដ្ឋាភិបាលរបស់លោក? ចុះការថ្លែងរបស់លោក ដើម្បីការពាររបបខ្មែរក្រហម នៅចំពោះមុខសម័យប្រជុំពេញអង្គរបស់អង្គការសហប្រជាជាតិក្នុងឆ្នាំ ១៩៧៦ និងការថ្លែងរបស់លោកទៅកាន់អង្គការសហប្រជាជាតិកាលពីថ្ងៃទី ២២ មករា ឆ្នាំ១៩៧៩ មានន័យយ៉ាងណា? លោកជាមនុស្សកុហក់? លោកជាមនុស្សបុគ្គលនិយម និងគ្រួសារនិយម? លោកជាមនុស្សបោកប្រាស់? តើទាំងអស់នេះលោកទទួលយកដែរឬទេ?

ខ្ញុំយល់ថា ទង្វើ និងទំលាប់ទទួលយកតែត្រូវ និងព្រមទទួលខុសដូចមនុស្សធុនលោក ក្រុមគ្រួសារលោក និងបក្ខពួករបស់លោក គឺពុំគួគប្បីនិងកើតមានជីវិតលើដីកម្ពុជាទៀតទេ នោះប្រសិនបើជាតិក្រោយពិតជាមាន លោក គ្រួសារលោក និងបក្ខពួក របស់លោក គួតែចាប់កំណើតក្នុងនៅប្រទេស ដែលលោកបានធ្វើពលិកម្មមួយជីវិតដើម្បីនោះ គឺប្រទេសយួន។

ដោយភាតរៈ និងការរាប់អាន។

**សួន សេរីរដ្ឋា**